កំណត់ត្រាសង្ខេប ៖ ទិវាសិទ្ធិលំនៅឋានពិភពលោក និងលំនៅឋានសមរម្យនៅកម្ពុជា

ទោះបីជាប្រជាជនរាប់សែននាក់បានវិលត្រឡប់ទៅកាន់លំនៅឋានរបស់ខ្លួនវិញ បន្ទាប់ពីការផ្លាស់ទីលំនៅទ្រង់ទ្រាយធំដែលបង្កឡើងដោយជម្លោះនៅតាមព្រំដែនកម្ពុជា-ថៃ កាលពីចុងឆ្នាំ២០២៥ ក៏ដោយ គ្រួសារជាច្រើននៅតែមិនអាចវិលត្រឡប់ទៅផ្ទះរបស់ខ្លួនវិញដោយសុវត្ថិភាពបានដែរ ដោយសារតែលំនៅឋាននោះបានរងការខូចខាត ការរំខានដល់ការផ្តល់សេវាកម្មនានា និងហានិភ័យពីគ្រាប់មិនទាន់ផ្ទុះ។ ក្រៅពីតំបន់ព្រំដែនជម្លោះដីធ្លីដែលអូសបន្លាយ ការកាន់កាប់ដីធ្លីដែលគ្មានសុវត្ថិភាព ការបណ្តេញចេញដោយបង្ខំ ឬការគំរាមកំហែងឱ្យចាកចេញ ការផ្តល់កម្ចីហិរញ្ញវត្ថុខ្នាតតូចដែលមានលក្ខណៈកេងប្រវ័ញ្ច និងការផ្លាស់ទីលំនៅដោយសារគម្រោងអភិវឌ្ឍន៍ បន្តបង្កហានិភ័យដល់លំនៅឋាន ដីធ្លី និងជីវភាពរស់នៅ។ សហគមន៍ជនជាតិដើមភាគតិចប្រឈមនឹងភាពងាយរងគ្រោះ ជាពិសេសដោយសារសម្ពាធនៃការអភិវឌ្ឍកាន់តែខ្លាំងឡើងៗ ដែលជះឥទ្ធិពលលើដីធ្លីតាមបែបប្រពៃណី និងជាមូលដ្ឋានសម្រាប់លំនៅឋាន ជីវភាពរស់នៅ និងការអាស្រ័យផលតាមវប្បធម៌របស់ពួកគេ។

ក្នុងបរិបទនេះ ទិវាសិទ្ធិលំនៅឋានពិភពលោកឆ្នាំ២០២៦ដែលប្រព្រឹត្តទៅក្រោមប្រធានបទ «លំនៅឋានសមស្របសម្រាប់ទាំងអស់គ្នា» គឺជាឱកាសសំខាន់ដើម្បីលើកឡើងពីតម្រូវការជាក់ស្តែងនៃលំនៅឋាន សមស្រប។ ក្នុងចំណោមសមាសធាតុផ្សេងៗទៀត ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ក.អ.ស.ស.ស.វ) លំនៅឋានសមរម្យតម្រូវឱ្យមានសុវត្ថិភាពនៃសិទ្ធិកាន់កាប់ ការទទួលបានសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធ លក្ខខណ្ឌរស់នៅសមរម្យ លទ្ធភាពក្នុងការចូលប្រើប្រាស់ទីតាំងសមស្របនិងភាពសមស្របតាមទិដ្ឋភាពវប្បធម៌។ នៅក្នុងកំណត់ត្រាសង្ខេបនេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) ពិនិត្យមើលបញ្ហាប្រឈមនានាក្នុងពេលបច្ចុប្បន្នពាក់ព័ន្ធនឹងសិទ្ធិទទួលបានលំនៅឋានសមរម្យនៅក្នុងប្រទេសកម្ពុជា ព្រមទាំងបង្ហាញអំពីបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធនឹងសុវត្ថិភាពនៃការកាន់កាប់លំនៅឋាន ការបណ្តេញចេញដោយបង្ខំ ការផ្លាស់ទីលំនៅ និងការវិលត្រឡប់មកវិញ។ ជាចុងក្រោយ ម.ស.ម.ក អំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា ធានាថាប្រជាជនគ្រប់រូបនៅក្នុងប្រទេសកម្ពុជាត្រូវបានការពារពីការបណ្តេញចេញដោយបង្ខំ និងការផ្លាស់ទីលំនៅ ទទួលបានការពិគ្រោះយោបល់ និងសំណងសមរម្យ រួមទាំងត្រូវបានរៀបចំទីតាំងរស់នៅថ្មីក្នុងករណីដែលមិនអាចជៀសវាងពីការផ្លាស់ទីលំនៅបាន ហើយអាចវិលត្រឡប់ទៅកាន់លំនៅឋានរបស់ខ្លួនវិញដោយសុវត្ថិភាព និងមាននិរន្តរភាព ប្រសិនបើពួកគេត្រូវបានផ្លាស់ទីលំនៅ។

ស្ថានភាពនៅកម្ពុជា

ភាពមិនច្បាស់លាស់នៃសិទ្ធិកាន់កាប់ដីធ្លីនៅតែធ្វើឱ្យសហគមន៍នានាទូទាំងប្រទេសកម្ពុជាប្រឈមនឹងហានិភ័យនៃការបាត់បង់ដីធ្លី ផ្ទះសម្បែង និងមធ្យោបាយចិញ្ចឹមជីវិត។ ជម្លោះដ៏រុំរ៉ែពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ចនៅតែមិនទាន់ត្រូវបានដោះស្រាយ ខណៈដែលសហគមន៍ជាច្រើននៅតែបន្តប្រឈមនឹងការបណ្តេញចេញដោយបង្ខំ ឬការគំរាមកំហែងបណ្តេញចេញ។ តាមការឃ្លាំមើលរបស់ ម.ស.ម.ក បានរកឃើញករណីចំនួន ៤០ ករណីពាក់ព័ន្ធនឹងការបណ្តេញចេញដោយបង្ខំ ឬការគំរាមកំហែងបណ្តេញចេញ ដែលប៉ះពាល់ដល់គ្រួសារចំនួន ២២.១០៨ គ្រួសារ នៅចន្លោះខែតុលា ឆ្នាំ២០២៣ និងខែកញ្ញា ឆ្នាំ២០២៤។ ករណីទាំងនេះរួមមានសកម្មភាពដូចជា ការគំរាមកំហែង ការបំផ្លាញទ្រព្យសម្បត្តិ ការផ្តល់សំណងមិនសមស្រប និងការខ្វះការពិគ្រោះយោបល់គ្រប់គ្រាន់។ និន្នាការទាំងនេះនៅតែបន្តរហូតដល់ឆ្នាំ ២០២៦។ នៅខែកក្កដា ឆ្នាំ២០២៦ ប្រជាជនប្រមាណ ៣០០គ្រួសារ ដែលរងផលប៉ះពាល់ដោយសារសម្បទានដីសេដ្ឋកិច្ច ដែលបានផ្តល់ទៅឱ្យក្រុមហ៊ុន ហ្ត្រេតវ៉នឌ៉រអេហ្ត្រីខលឈ័រ ឌឺវេឡូបមេន នៅក្នុងខេត្តក្រចេះ ត្រូវបានបញ្ជាឱ្យចាកចេញពីលំនៅឋាន ដីដំណាំ និងទីតាំងសាងសង់របស់ពួកគេ ត្រឹមថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០២៦។

ការផ្តល់កម្ចីហិរញ្ញវត្ថុខ្នាតតូចក្នុងលក្ខណៈកេងប្រវ័ញ្ច និងទារបំណុលដោយបង្ខំ ក៏ជាកត្តាចម្បងមួយដែលនាំឱ្យមានការបាត់បង់ដីធ្លីនៅក្នុងប្រទេសកម្ពុជា ជាពិសេសក្នុងចំណោមអ្នកខ្ចីប្រាក់ដែលជាជនក្រីក្រ និងជនជាតិដើមភាគតិច។ គ្រឹះស្ថានហិរញ្ញវត្ថុខ្នាតតូចបានផ្សព្វផ្សាយ និងផ្តល់កម្ចីយ៉ាងសកម្មដល់សហគមន៍ជនជាតិដើមភាគតិច ដោយជារឿយៗផ្តល់កម្ចីដោយផ្អែកជាចម្បងលើតម្លៃដីធ្លីរបស់អ្នកខ្ចី ជាជាងផ្អែកលើលទ្ធភាពក្នុងការសងប្រាក់វិញរបស់ពួកគេ។ ជនជាតិដើមភាគតិចជាច្រើនដែលខ្ចីប្រាក់បានជួបឧបសគ្គផ្នែកភាសា និងកង្វះចំណេះដឹងផ្នែកហិរញ្ញវត្ថុ ខណៈដែលអ្នកខ្លះនៅតែទទួលបានការផ្តល់ជូនប្រាក់កម្ចី ទោះបីជាពួកគេកំពុងជួបការលំបាកក្នុងការសងបំណុលក៏ដោយ។ ជាលទ្ធផល អ្នកខ្ចីប្រាក់ត្រូវបានដាក់សម្ពាធឱ្យលក់ដីធ្លី និងទ្រព្យសកម្មផលិតកម្មផ្សេងទៀត ដែលនាំឱ្យបាត់បង់ដីធ្លី និងប៉ះពាល់ដល់ជីវភាពរស់នៅ ព្រមទាំងប៉ះពាល់ដល់សិទ្ធិលើដីធ្លីជាសមូហភាព អត្តសញ្ញាណវប្បធម៌ និងរបៀបរស់នៅតាមបែបប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច។

ទន្ទឹមនឹងនេះទោះជាមានឯកសារបញ្ជាក់ពីកង្វះខាតក្នុងការពិគ្រោះយោបល់ និងការផ្តល់សំណងដល់សហគមន៍ដែលរងផលប៉ះពាល់ដោយគម្រោងអភិវឌ្ឍន៍ធំៗក៏ដោយ ក៏ការអនុម័តលើគម្រោងវិនិយោគនៅតែបន្តកើនឡើងយ៉ាងឆាប់រហ័ស ដែលបង្កើនហានិភ័យនៃផលប៉ះពាល់លើដីធ្លី និងលំនៅឋាន ក្នុងករណីដែលគ្មានការអនុវត្តវិធានការការពារសមស្រប។ កម្ពុជា

> នៅខែមេសា ឆ្នាំ២០២៦ ប្រជាជនដែលប្រឈមនឹងការរុះរើលំនៅឋានសម្រាប់ការងារពង្រីកប្រឡាយបឹងត្របែក បានបដិសេធលំនៅឋានសម្រាប់ផ្លាស់ទីលំនៅដែលអាជ្ញាធរបានស្នើឡើង ដោយបានអះអាងថា មានលក្ខណៈមិនសមស្រប ដោយសារទំហំតូច ទីតាំងនៅឆ្ងាយពីទីក្រុង និងងាយរងគ្រោះដោយទឹកជំនន់។ ទោះជាយ៉ាងណាក៏ដោយ អាជ្ញាធរ បានបញ្ជាឱ្យប្រជាជនរុះរើផ្ទះសម្បែងរបស់ខ្លួន និងបានព្រមានថា សំណង់ដែលនៅសេសសល់នឹងត្រូវរុះរើចោល។

បានអនុម័តលើគម្រោងវិនិយោគទ្រព្យសកម្មថេរចំនួន ៦៣០ គម្រោងក្នុងឆ្នាំ ២០២៥ ដែលកើនឡើង ៥២% បើធៀបក្នុងឆ្នាំ ២០២៤ រួមទាំងគម្រោងធំៗផ្នែកកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងថាមពល ហើយបន្ទាប់មកមានគម្រោងចំនួន ១៤៦ ទៀតនៅក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៦។

គម្រោងព្រែកជីកហ្វូណន-តេជោ ដែលមានប្រវែង១៨០ គីឡូម៉ែត្រ រំពឹងថានឹងអាចប៉ះពាល់ដល់គ្រួសារយ៉ាងហោចណាស់ ២.៣០៥ គ្រួសារ ដែលក្នុងនោះមានប្រមាណចំនួន ៤០០ គ្រួសារ ត្រូវប្រឈមនឹងបាត់បង់លំនៅឋានរបស់ខ្លួន។ ត្រឹមខែសីហា ឆ្នាំ២០២៦ គ្រួសារមួយចំនួនបានបាត់បង់លទ្ធភាពប្រើប្រាស់ដីកសិកម្មរួចទៅហើយ ខណៈដែលការផ្តល់សំណងសម្រាប់ដីកសិកម្ម និងអចលនទ្រព្យលំនៅឋានដែលរងផលប៉ះពាល់ នៅតែមិនទាន់មានភាពច្បាស់លាស់នៅឡើយ។

សម្ពាធទាំងនេះមានភាពធ្ងន់ធ្ងរជាពិសេសសម្រាប់សហគមន៍ជនជាតិដើមភាគតិច ដែលសហគមន៍ជាច្រើននៅមិនទាន់ទទួលបានការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីធ្លីជាសមូហភាព (ប.ក.ដ.ស) ពេញលេញនៅឡើយ។ ទោះបីជាមានវឌ្ឍនភាពពីចំនួន ៤៣ ប.ក.ដ.ស កាលពីខែមិថុនា ឆ្នាំ២០២៥ មកដល់ ៥៩ ប.ក.ដ.ស គិតត្រឹមខែ មិថុនា ឆ្នាំ២០២៦ ក៏ដោយ ក៏មានតែ ១២% ប៉ុណ្ណោះនៃសហគមន៍ជនជាតិដើមភាគតិចនៅ កម្ពុជា (ដែលត្រូវបានប៉ាន់ប្រមាណថាមានចំនួន ៤៨៨ សហគមន៍) បានទទួលប័ណ្ណកម្មសិទ្ធិដីទាំងនេះ ខណៈដែលដំណើរក្នុងការចុះបញ្ជី នៅតែមានភាពស្មុគស្មាញ ចំណាយច្រើន និងប្រើប្រាស់ពេលវេលាយូរ។ នៅខែកញ្ញា ឆ្នាំ២០២៦ គ្រួសារជនជាតិដើមភាគតិចឆ្នងប្រមាណ ១៥០ គ្រួសារ នៅក្នុងខេត្តមណ្ឌលគិរី បានរាយការណ៍ថា មានការឈូសឆាយដីសម្រាប់គម្រោងអភិវឌ្ឍន៍ឯកជន បានប៉ះពាល់ដល់ដីកសិកម្មដែលធ្វើស្រែចម្ការរំលងជុំ កន្លែងបញ្ចុះសព និងព្រៃសក្ការៈ ព្រមទាំងបង្កការគំរាមកំហែងដល់ប្រភពទឹក តំបន់នេសាទ និង លទ្ធភាពក្នុងការអាស្រ័យផលធនធានព្រៃឈើដែលចាំបាច់សម្រាប់ជីវភាពរស់នៅរបស់សហគមន៍។ សហគមន៍ ដែលបានព្យាយាមតវ៉ានឹងការបណ្តេញចេញ ឬស្វែងរកដំណោះស្រាយ ជារឿយៗជួបប្រទះនឹងការរឹតត្បិត និងការគំរាមកំហែង។ នៅខែកក្កដា ឆ្នាំ២០២៦ អាជ្ញាធរ បានរារាំងប្រជាជនមកពីខេត្តក្រចេះមិនឱ្យដើរហែក្បួនទៅកាន់រដ្ឋសភា ដើម្បីស្នើសុំដំណោះស្រាយជុំវិញបញ្ហាវិវាទដីធ្លីដែលពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច ខណៈនៅក្នុងខែឧសភា តំណាងសហគមន៍ដីធ្លីមួយរូបនៅខេត្តព្រះវិហារ ត្រូវបានប៉ូលិសស្រុកកោះហៅ ហើយបានរាយការណ៍ថាខ្លួនទទួលរងសម្ពាធឱ្យបញ្ឈប់ការតវ៉ា និងការដាក់ញត្តិ។

> ពាក់ព័ន្ធនឹងការកែសម្រួលផ្លូវនៃគម្រោងព្រែកជីកហ្វូណន-តេជោ គ្រួសារមួយនៅក្នុងស្រុកអង្គរបូរីមិនអាចធ្វើស្រែលើផ្ទៃដីទំហំ ១,៥ ហិកតាបានឡើយ ចាប់តាំងពីខែវិច្ឆិកា ឆ្នាំ ២០២៥ មក ទោះបីជាមិនទាន់ទទួលបានប្រាក់សំណងក៏ដោយ ខណៈដែលដីលំនៅឋានរបស់ពួកគេក៏រងផលប៉ះពាល់ផងដែរ។ នៅខែមករា ឆ្នាំ២០២៦ កសិករម្នាក់ក្នុងខេត្តកណ្តាលបានរាយការណ៍ថា គាត់មិនមានព័ត៌មានអំពីទីតាំងដែលត្រូវផ្លាស់ប្តូរទីលំនៅ ឬចំនួនទឹកប្រាក់សំណងដែលនឹងទទួលបាននោះទេ បន្ទាប់ពីមានការរំពឹងទុកថាផ្ទះរបស់គាត់នឹងត្រូវរុះរើ។

ទោះជាមានបទឈប់បាញ់ក៏ដោយ ការផ្លាស់ទីលំនៅដោយសារជម្លោះរវាងកម្ពុជានិងថៃ នៅតែបន្តប៉ះពាល់ដល់លទ្ធភាពរបស់ប្រជាជនកម្ពុជាជាច្រើនក្នុងការទទួលបានលំនៅឋានសមរម្យ។ នៅក្នុងស្ថានភាពក្តៅគគុកនៃជម្លោះក្នុងខែធ្នូ ឆ្នាំ២០២៥ ជម្លោះនៅតាមព្រំដែនបានបង្កឱ្យមានការផ្លាស់ទីលំនៅរបស់ប្រជាជនចំនួន ៦៤៤.៥៨៩ នាក់នៅទូទាំងប្រទេសកម្ពុជា។ ទោះបីជាភាគច្រើនបានវិលត្រឡប់ទៅវិញហើយក៏ដោយ ប៉ុន្តែនៅចុងខែកក្កដា ឆ្នាំ២០២៦ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ លោក ចូម៉ាស អេនឌ្រូ បានកត់សម្គាល់ថានៅមានជនស៊ីវិលកម្ពុជាចំនួន ២០.០០០នាក់ទៀត ដែលនៅតែត្រូវផ្លាស់ទីលំនៅ និងមិនអាចវិលត្រឡប់ទៅផ្ទះវិញបាន។ គិតត្រឹមខែកញ្ញា ឆ្នាំ២០២៦ ប្រជាជនចំនួន ១៣.២៥៩នាក់ នៅក្នុងជំរុំជនភៀសសឹកស៊ីវិលដែលត្រូវផ្លាស់ទីលំនៅ នៅឯភូមិរង់ចាំ នៅតែមិនអាចវិលត្រឡប់ទៅកាន់លំនៅឋានរបស់ពួកគេវិញបានឡើយ។ ខណៈគ្រួសារជនភៀសសឹករាប់ពាន់នាក់បានផ្លាស់ទីលំនៅពីជម្រកបណ្តោះអាសន្នទៅនៅក្នុងលំនៅឋានបណ្តោះអាសន្ន ឱកាសចិញ្ចឹមជីវិតមានការខ្វះខាត ការផ្គត់ផ្គង់ទឹកមិនបានគ្រប់គ្រាន់ សម្ភារៈបង្រៀន និងសម្ភារៈសិក្សានៅមានកម្រិត និងផ្លូវដើរទទួលរងទឹកជំនន់នៅតែបន្តធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅ។ ការខូចខាតផ្ទះសម្បែង និងហេដ្ឋារចនាសម្ព័ន្ធ យុទ្ធកណ្តាលមិនទាន់ផ្ទុះ និងលក្ខខណ្ឌមិនទាន់ដោះស្រាយនៅតាមផ្នែកខ្លះនៃព្រំដែន ក៏បន្តរារាំងការវិលត្រឡប់ទៅលំនៅឋានវិញប្រកបដោយសុវត្ថិភាព និងនិរន្តរភាពផងដែរ។

ច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ

សិទ្ធិទទួលបានលំនៅឋានសមរម្យត្រូវបានធានាដោយ មាត្រា១១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ក.អ.ស.ស.ស.វ) ដែលកម្ពុជាបានផ្តល់សច្ចាប័ននៅឆ្នាំ១៩៩២។ ដូចដែលបានបញ្ជាក់យ៉ាងច្បាស់ដោយគណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌នៅក្នុងសេចក្តីអត្ថាធិប្បាយទូទៅលេខ ៤ លំនៅឋានសមរម្យមិនគួរត្រូវបានយល់ថាគ្រាន់តែជាទីជម្រកខាងរូបវន្តប៉ុណ្ណោះទេ ប៉ុន្តែជាសិទ្ធិក្នុងការរស់នៅក្នុងទីកន្លែងមួយប្រកបដោយសុវត្ថិភាព សន្តិភាព និងសេចក្តីថ្លៃថ្នូរ។ ភាពសមរម្យនេះរួមបញ្ចូលនូវធាតុផ្សំចំនួន ៧ ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមករួមមាន៖ សុវត្ថិភាពផ្លូវច្បាប់នៃការកាន់កាប់លំនៅឋាន ភាពអាចទទួលបានសេវាកម្ម សម្ភារៈ គ្រឿងបរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធ តម្លៃសមរម្យ លក្ខខណ្ឌរស់នៅសមស្របលទ្ធភាពទទួលបាន ទីតាំង និងភាពសមស្របតាមវប្បធម៌។

ដូចនេះ សុវត្ថិភាពនៃការកាន់កាប់គឺជាផ្នែកដ៏សំខាន់មួយនៃសិទ្ធិទទួលបានលំនៅឋានសមរម្យ។ សេចក្តីអត្ថាធិប្បាយទូទៅលេខ ២៦ ស្តីពីដីធ្លី និងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ក៏បានទទួលស្គាល់ផងដែរថា ការទទួលបាន ការប្រើប្រាស់ និងការគ្រប់គ្រងដីធ្លីប្រកបដោយសុវត្ថិភាព និងសមធម៌ គឺជាកត្តាចាំបាច់សម្រាប់ការទទួលបានកម្រិតជីវភាពរស់នៅសមរម្យ រួមទាំងលំនៅឋានសមរម្យផងដែរ ហើយការបាត់បង់លទ្ធភាពបែបនេះអាចនាំឱ្យមានការផ្លាស់ទីលំនៅ និងការបណ្តេញចេញដោយបង្ខំ។ ចំពោះជនជាតិដើមភាគតិច ទំនាក់ទំនងរវាងដីធ្លីនិងលំនៅឋានសមរម្យមានសារៈសំខាន់ជាពិសេស ដោយសារលំនៅឋាន ជីវភាពរស់នៅ ទំនៀមទម្លាប់វប្បធម៌និងអត្តសញ្ញាណរបស់ពួកគេ តែងតែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងដីធ្លី និងទឹកដីតាមបែប

ប្រពៃណីរបស់ខ្លួន។ ដូច្នេះ ការការពារទូទៅចំពោះសិទ្ធិទទួលបានលំនៅឋានសមរម្យ ត្រូវបានបំពេញបន្ថែមដោយការការពារជាក់លាក់នានា ដែលមានចែងក្នុងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច (ស.ប.ស.ស.ជ.ក)។ សេចក្តីប្រកាសនេះទទួលស្គាល់សិទ្ធិរបស់ពួកគេលើដីធ្លី ដែនដី និងធនធានដែលពួកគេធ្លាប់កាន់កាប់ ប្រើប្រាស់ ឬទទួលបានតាមបែបប្រពៃណី ហើយតម្រូវឱ្យរដ្ឋផ្តល់ការទទួលស្គាល់ និងការការពារតាមផ្លូវច្បាប់ ដោយគោរពយ៉ាងត្រឹមត្រូវចំពោះទំនៀមទម្លាប់ ប្រពៃណី និងប្រព័ន្ធកាន់កាប់ដីធ្លីរបស់ជនជាតិដើមភាគតិច។ លើសពីនេះ ស.ប.ស.ស.ជ.ក ចែងថា ជនជាតិដើមភាគតិចមិនត្រូវបានបង្ខំឱ្យចាកចេញពីដីធ្លី ឬដែនដីរបស់ពួកគេឡើយ ប្រសិនបើគ្មានការយល់ព្រមដោយស្មគ្រចិត្ត និងដោយបានទទួលព័ត៌មានគ្រប់គ្រាន់ជាមុន ព្រមទាំងមានកិច្ចព្រមព្រៀងលើសំណងដ៏យុត្តិធម៌ និងសមស្របនោះទេ ហើយពួកគេក៏ត្រូវមានជម្រើសក្នុងការវិលត្រឡប់ទៅកាន់ទឹកដីដើមវិញផងដែរ ប្រសិនបើអាចធ្វើទៅបាន។

ការបាត់បង់លំនៅឋាន ដីធ្លី និងទ្រព្យសម្បត្តិ អាចជះឥទ្ធិពលអវិជ្ជមានមិនត្រឹមតែទៅលើលទ្ធភាពទទួលបានលំនៅឋានសមរម្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់លទ្ធភាពទទួលបានស្បៀងអាហារ ទឹកស្អាត និងអនាម័យ សេវាសុខភាព និងមធ្យោបាយចិញ្ចឹមជីវិត ព្រមទាំងរារាំងដល់សមត្ថភាពរបស់បុគ្គលក្នុងការរស់នៅដោយសុវត្ថិភាពនៅក្នុងលំនៅឋាន និងសហគមន៍របស់ពួកគេផងដែរ។

មតិទូទៅលេខ ៧ ផ្តល់ការការពារជាក់លាក់ប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ ដែលជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិទទួលបានលំនៅឋានសមរម្យ។ ដើម្បីបំពេញបន្ថែមលើចំណុចនេះ មាត្រា១៧ នៃ ក.អ.ស.ព.ន ហាមឃាត់ការជ្រៀតជ្រែកតាមអំពើចិត្ត ឬខុសច្បាប់ជាមួយផ្ទះរបស់បុគ្គល។ ដោយមិនគិតពីស្ថានភាពកាន់កាប់នោះទេ មនុស្សគ្រប់រូបគួរតែទទួលបានសុវត្ថិភាពនៃការកាន់កាប់ក្នុងកម្រិតមួយ ដើម្បីការពារពួកគេពីការបណ្តេញចេញដោយបង្ខំ ការយាយី និងការគំរាមកំហែងផ្សេងៗទៀត។ មុនពេលមានការបណ្តេញចេញណាមួយ រដ្ឋត្រូវតែស្វែងយល់ពីជម្រើសដែលអាចធ្វើទៅបានទាំងអស់ ដោយពិគ្រោះយោបល់យ៉ាងពិតប្រាកដជាមួយជនដែលរងផលប៉ះពាល់ និងធានាការការពារនីតិវិធីសមស្រប និងការទទួលបានដំណោះស្រាយ។ ការបណ្តេញចេញមិនត្រូវធ្វើឱ្យបុគ្គលគ្មានផ្ទះសម្បែង ឬងាយរងគ្រោះដោយសារការរំលោភសិទ្ធិមនុស្សបន្ថែមទៀតឡើយ។ ការការពារទាំងនេះត្រូវបានបញ្ជាក់បន្ថែមនៅក្នុង គោលការណ៍ណែនាំជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីការបណ្តេញចេញ និងការផ្លាស់ទីលំនៅដោយផ្អែកលើការអភិវឌ្ឍ ដែលចែងថាការបណ្តេញចេញទាក់ទងនឹងការអភិវឌ្ឍអាចកើតឡើងតែក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ ហើយតម្រូវឱ្យមានការចូលរួមដ៏មានអត្ថន័យ សំណងសមរម្យ និងការតាំងទីលំនៅថ្មីគ្រប់គ្រាន់ ក្នុងចំណោមការការពារផ្សេងទៀត។ ក្នុងករណីដែលការផ្លាស់ទីលំនៅ ឬការបណ្តេញចេញកើតឡើងដោយខុសច្បាប់ អ្នកដែលរងផលប៉ះពាល់ត្រូវតែមានលទ្ធភាពទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព រួមទាំងការសងប្រាក់វិញ និងសំណងសមស្រប។ មាត្រា ២ (៣) នៃ ក.អ.ស.ព.ន តម្រូវឱ្យរដ្ឋធានានូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ក្នុងករណីដែលសិទ្ធិដែលការពារដោយកតិកាសញ្ញាត្រូវបានរំលោភបំពាន។ ដូច្នេះ កាតព្វកិច្ចក្នុងការផ្តល់ដំណោះស្រាយពង្រីកលើសពី

ការការពារការបាត់បង់លំនៅឋានឬដីធ្លីដំបូង រហូតដល់ការដោះស្រាយផលវិបាក និងកន្លែងដែលអាចធ្វើទៅបាន និងស្តារស្ថានភាពអ្នកដែលរងផលប៉ះពាល់ត្រឡប់ទៅរកស្ថានភាពដើមរបស់ពួកគេវិញ។

ការការពារដែលមានចែងនៅក្នុង ក.អ.ស.ស.ស.វ និង ក.អ.ស.ព.ន រួមទាំងសិទ្ធិទទួលបានលំនៅឋានសមរម្យ ការការពារប្រឆាំងនឹងការជ្រៀតជ្រែកដោយបំពាន ឬខុសច្បាប់មកលើលំនៅឋាន និងសិទ្ធិទទួលបានដំណោះស្រាយដ៏មានប្រសិទ្ធភាពនោះ នៅតែបន្តមានសុពលភាពក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធ ទន្ទឹមនឹងការអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិ។ ចំពោះជនដែលត្រូវផ្លាស់ទីលំនៅនៅក្នុងប្រទេសដោយសារជម្លោះ ការការពារទាំងនេះក៏គ្របដណ្តប់លើការទប់ស្កាត់ការផ្លាស់ទីលំនៅដោយបំពាន ការធានានូវលក្ខខណ្ឌរស់នៅសមរម្យក្នុងអំឡុងពេលផ្លាស់ទីលំនៅ និងការសម្របសម្រួលដល់ការវិលត្រឡប់ ឬការតាំងទីលំនៅថ្មីដោយស្ម័គ្រចិត្ត ប្រកបដោយសុវត្ថិភាពនិងសេចក្តីថ្លៃថ្នូរ។ គោលការណ៍ណែនាំស្តីពីការផ្លាស់ទីលំនៅនៅក្នុងប្រទេស ផ្តល់នូវក្របខ័ណ្ឌអន្តរជាតិដ៏សំខាន់មួយ ដែលប្រមូលផ្តុំនូវស្តង់ដារច្បាប់សិទ្ធិមនុស្ស និងច្បាប់មនុស្សធម៌អន្តរជាតិពាក់ព័ន្ធ ដើម្បីការពារជនដែលត្រូវផ្លាស់ទីលំនៅនៅក្នុងប្រទេសដោយសារជម្លោះ និងមូលហេតុផ្សេងទៀត រួមទាំងក្នុងអំឡុងពេលវិលត្រឡប់ និងការតាំងទីលំនៅថ្មីផងដែរ។

គោលការណ៍ខាងក្រោមនេះគឺមានសារៈសំខាន់ណាស់ចំពោះបរិបទនៃប្រទេសកម្ពុជាបច្ចុប្បន្ន៖

គោលការណ៍ទី ៧ ៖ មុននឹងសម្រេចចិត្តណាមួយដែលតម្រូវឱ្យមានការបម្លាស់ទីលំនៅរបស់ប្រជាជន អាជ្ញាធរត្រូវតែធានាថារាល់ជម្រើសដែលអាចធ្វើទៅបានត្រូវបានពិនិត្យមើល ដើម្បីជៀសវាងការបម្លាស់ទីលំនៅទាំងស្រុង។ ក្នុងករណីដែលគ្មានជម្រើសផ្សេងទៀត ត្រូវចាត់វិធានការគ្រប់យ៉ាងដើម្បីកាត់បន្ថយការបម្លាស់ទីលំនៅ និងផលប៉ះពាល់អវិជ្ជមានរបស់វាឱ្យនៅកម្រិតទាបបំផុត។

គោលការណ៍ទី ៩ ៖ រដ្ឋមានកាតព្វកិច្ចសំខាន់ក្នុងការការពារទល់នឹងការបម្លាស់ទីលំនៅរបស់ជនជាតិដើមភាគតិច ជនជាតិភាគតិច កសិករ អ្នកចិញ្ចឹមសត្វ និងក្រុមផ្សេងទៀតដែលមានការពឹងផ្អែក និងការផ្សារភ្ជាប់យ៉ាងពិសេសទៅនឹងដីធ្លីរបស់ពួកគេ។

គោលការណ៍ទី ២៨ ៖ អាជ្ញាធរមានសមត្ថកិច្ចមានភារកិច្ច និងទំនួលខុសត្រូវចម្បងក្នុងការបង្កើតលក្ខខណ្ឌ ព្រមទាំងផ្តល់មធ្យោបាយ ដែលអនុញ្ញាតឱ្យជនភៀសសឹកក្នុងស្រុកអាចវិលត្រឡប់ដោយស្ម័គ្រចិត្ត ប្រកបដោយសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ ទៅកាន់លំនៅឋាន ឬទីកន្លែងរស់នៅធម្មតារបស់ពួកគេ ឬដើម្បីតាំងទីលំនៅថ្មីដោយស្ម័គ្រចិត្ត នៅផ្នែកផ្សេងទៀតនៃប្រទេស។

គោលការណ៍ទី ២៩៖ អាជ្ញាធរមានសមត្ថកិច្ចមានភារកិច្ច និងទំនួលខុសត្រូវក្នុងការជួយដល់ជនភៀសសឹកក្នុងស្រុកដែលបានវិលត្រឡប់ និង/ឬបានតាំងទីលំនៅថ្មី ដើម្បីទាមទារយកមកវិញ ក្នុងកម្រិតដែលអាចធ្វើទៅបាននូវទ្រព្យសម្បត្តិ និងសម្ភារៈរបស់ពួកគេដែលបានបោះបង់ចោល ឬត្រូវបានដកហូតយកទៅនៅពេលដែលពួកគេត្រូវបានបម្លាស់ទីលំនៅ។ នៅពេលដែលការទាមទារយកទ្រព្យសម្បត្តិ និងសម្ភារៈទាំង

នោះមកវិញមិនអាចធ្វើទៅបាន អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្តល់ឬជួយដល់បុគ្គលទាំងនេះក្នុងការទទួលបានសំណងសមស្របឬទម្រង់ផ្សេងទៀតនៃការជួសជុលដ៏ត្រឹមត្រូវមួយ។

អនុសាសន៍

ម.ស.ម.ក អំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា ចាត់វិធានការដូចខាងក្រោម ដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវសិទ្ធិទទួលបានលំនៅឋានសមរម្យ ៖

១. ទប់ស្កាត់ការបណ្តេញចេញដោយបង្ខំ និងពង្រឹងសុវត្ថិភាពនៃការកាន់កាប់លំនៅឋាន ដោយផ្អាកការបណ្តេញចេញដែលមិនអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ស្វែងរកជម្រើសផ្សេងៗដែលអាចធ្វើទៅបានដើម្បីចៀសវាងការផ្លាស់ទីលំនៅ និងធានាថាការបណ្តេញចេញណាមួយដែលធ្វើឡើង នឹងមិនបណ្តាលឱ្យមានភាពគ្មានផ្ទះសម្បែង ឬបង្កើនភាពងាយរងគ្រោះឡើយ។

២. ធានាឱ្យមានការពិគ្រោះយោបល់ទាន់ពេលវេលា និងប្រកបដោយអត្ថន័យជាមួយសហគមន៍ដែលរងផលប៉ះពាល់ដោយគម្រោងអភិវឌ្ឍន៍ ផ្តល់ព័ត៌មានច្បាស់លាស់អំពីការផ្លាស់ទីលំនៅដែលអាចកើតមាន ការផ្តល់សំណង និងការតាំងទីលំនៅថ្មី ព្រមទាំងធានាឱ្យមានការផ្តល់សំណងដោយយុត្តិធម៌ មុនពេលការផ្លាស់ទីលំនៅកើតឡើង។

៣. ធានាថារាល់ការផ្លាស់ទីលំនៅណាមួយដែលនឹងកើតឡើង ត្រូវផ្តល់លំនៅឋានជំនួសដ៏សមស្របរួមទាំងសុវត្ថិភាពនៃសិទ្ធិកាន់កាប់លំនៅឋាន សេវាកម្មចាំបាច់ លក្ខខណ្ឌរស់នៅសមរម្យ ទីតាំងសមស្របនិងលទ្ធភាពទទួលបានមធ្យោបាយរកប្រាក់ចំណូល។

៤. ពង្រឹងនិងអនុវត្តបទប្បញ្ញត្តិស្តីពីការផ្តល់កម្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការអនុវត្តការទារបំណុល ដោយសហការជាមួយធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរពាក់ព័ន្ធ។ វិធានការទាំងនេះរួមមានការតម្រូវឱ្យមានការវាយតម្លៃលើលទ្ធភាពសងត្រឡប់របស់អ្នកខ្ចីប្រាក់ ការធានាឱ្យមានលក្ខខណ្ឌកម្ចីដែលអាចចូលប្រើប្រាស់ និងងាយយល់បាន ការទប់ស្កាត់ការអនុវត្តការទារបំណុលបែបបង្ខិតបង្ខំ និងការការពារជីវិភាពរបស់ជនជាតិដើមភាគតិចពីការបាត់បង់ដោយសារបញ្ហាបំណុល។

៥. ពន្លឿន និងសម្រួលដល់ដំណើរការចុះបញ្ជី ប.ក.ដ.ស សម្រាប់សហគមន៍ជនជាតិដើមភាគតិចព្រមទាំងការពារដីធ្លីតាមបែបប្រពៃណីក្នុងអំឡុងពេលរង់ចាំការចុះបញ្ជី (រួមទាំងការការពារទល់នឹងការរំលោភបំពាន ការផ្តល់សម្បទាន និងគម្រោងអភិវឌ្ឍន៍នានា) ដោយធានាឱ្យមានការចូលរួមប្រកបដោយអត្ថន័យ និងការគោរពចំពោះគោលការណ៍នៃការយល់ព្រមដោយសេរី ផ្អែកលើព័ត៌មានពេញលេញ និងមុនពេលចាប់ផ្តើមសកម្មភាព ស្របតាមបទដ្ឋានអន្តរជាតិ។

៦. ធានាថាសហគមន៍អាចការពារសិទ្ធិលើដីធ្លី និងលំនៅឋានរបស់ខ្លួនបាន ដោយគ្មានការគំរាមកំហែងការរារាំង ឬការសងសឹក ហើយបង្កើត ឬពង្រឹងយន្តការដោះស្រាយវិវាទ និងប្រព័ន្ធទទួលពាក្យបណ្តឹង

ដែលងាយស្រួលចូលទៅប្រើប្រាស់បាន និងផ្តល់ជំណោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះករណីបណ្តេញចេញ ការបាត់បង់ដីធ្លី និងអ្នកទទួលសំណងមិនសមរម្យ។

៧. សម្រួលដល់ការវិលត្រឡប់ដោយសុវត្ថិភាពដោយស្មគ្រចិត្ត និងប្រកបដោយនិរន្តរភាព សម្រាប់អ្នកដែលនៅតែបន្តផ្លាស់ទីលំនៅដោយសារជម្លោះរវាងកម្ពុជានិងថៃ តាមរយៈការដោះស្រាយឧបសគ្គនានាដែលរារាំងដល់ការវិលត្រឡប់រួមទាំងគ្រាប់មិនទាន់ផ្ទុះនិងការខូចខាតផ្ទះសម្បែង ឬហេដ្ឋារចនាសម្ព័ន្ធការរក្សាទុកនូវទីជម្រកបណ្តោះអាសន្ន និងសេវាកម្មចាំបាច់នានាឱ្យបានគ្រប់គ្រាន់រហូតដល់អាចវិលត្រឡប់បាន និងការផ្តល់ការសងត្រឡប់ ឬសំណងសមស្របក្នុងករណីដែលមិនអាចស្តារទ្រព្យសម្បត្តិឡើងវិញបាន។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក **វណ្ណ សុផាត** អ្នកសម្របសម្រួលគម្រោង ម.ស.ម.ក តាមរយៈទូរស័ព្ទលេខ (+៨៥៥) (០) ១២ ៩៤១ ២០៦ ឬអ៊ីមែល vann.sophath@cchrcambodia.org។